**Sources: http://khmersme.wordpress.com**

# ប្រវត្តិកំណាព្យខ្មែរ

១.អ្វីទៅ ជាកំណាព្យ

កំណាព្យ មកពីពាក្យថា កាព្យ(កាព្យឃ្លោង) គឺជាកម្រងពាក្យពេចន៍ ដែលកវី និពន្ធ លើកមកបរិយាយ អធិប្បាយ រៀបរាប់នូវរឿងអ្វីមួយ ដោយមានចំណាប់ចួន ក្នុងន័យបញ្ចិតបញ្ចៀង បត់បែន មិននិយាយ ដោយត្រង់ ដូចពាក្យរាយទេ តែមានកំណាត់ព្យាង្គច្បាស់លាស់។ កំណាព្យ គឺជាកម្រងពាក្យសម្តី ដែលមាន រូបារម្មណ៍ មានសោភណ្ឌ និងសម្ផស្សរបស់ពាក្យ ធ្វើឲ្យអ្នកអាន អ្នកស្តាប់ ជក់ចិត្តផងដែរ។ កំណាព្យ មិន មែនជាកម្រងកែវ ឬពាក្យរៀលទេ។

កំណាព្យ ឬកាព្យខ្មែរ មិនត្រូវបានគេរកឃើញថា ករកើតនៅឆ្នាំណានោះទេ ប៉ុន្តែ ឯកសារមួយចំនួន និង ភស្តុតាងជាក់ស្តែង ដែលចាស់បុរាណបានចងក្រង និងចារនៅលើជញ្ជាំងប្រាសាទ បង្ហាញថា កំណាព្យ ខ្មែរ មានកំណើតតាំងពីមុនសម័យអង្គរ។ អាចនិយាយបានថា តាំងពីកំណរកំណើតទឹកដីគោកធ្លកម្ល៉េះ។ កំណាព្យខ្មែរ ក៏ជាមធ្យោបាយ ក្នុងការចងក្រងប្រវត្តិសាស្រ្ត ក្បួនច្បាប់ទូន្មាន អប់រំនានា របស់ចាស់ បុរាណយើងដែរ ដែលគេអាចមើលឃើញនៅលើសាស្ត្រា ស្លឹករឹត ឬក្រាំងដទៃទៀតជាដើម។ ការចួនរណ្តំ របស់កំណាព្យ ចែកជាពីរបន្ថែមទៀត គឺចួនរណ្តំព្យាង្គ និង ចួនរណ្តំស្រៈ។

ក្នុងសៀវភៅមេកាព្យរបស់លោកអៀងសាយ បញ្ជាក់ថាមេកាព្យទាំងអស់មាន៤៦មេ និង មាន វិធីសូត្រ ប្រមាណជា៥៤បែបដែរ (54បទ)។

កំណាព្យខុសពីចម្រៀង កំណាព្យអាចយកធ្វើជាចម្រៀងបាន តែចម្រៀងមិនអាចយកមកធ្វើជាកំណាព្យ បាន ទេ។កំ ណាព្យ ខុសគ្នាផងដែរជាមួយនឹងកម្រងកែវ។

មនុស្សខ្មែរមួយចំនួន យល់ច្រឡំថា កម្រងកែវគឺជាកំណាព្យ ដែលធាតុពិតវាពុំមែននោះ ទេ។កម្រងកែវ គឺជា ពាក្យរាយមួបែប ដែល គេតែងតែនិយាយ និង សរសេរតាមបែប មួយ ដែលប្រហែលជាប្រទេស ដទៃគ្មាន។

ចំពោះចម្រៀងរបស់ខ្មែរមួយចំនួន គឺគេយកចេញពីសិល្បៈ កំណាព្យនេះឯង ដែលភាគ ច្រើនគឺបទពាក្យ ប្រាំពីរ ពាក្យប្រាំបី និងពាក្យប្រាំបួនជាដើម។កំណាព្យខ្មែរ មានដើមកំណើតតាំងពីបុរមបុរាណ ឬតាំងពី ការកកើតទឹកដី នៃនគរគោក ធ្លកមកម្ល៉េះ។ កំណាព្យ គឺជាឧបករណ៍ ដែលដូនតាខ្មែរយើងរាប់សិបជំនាន់ យកមកធ្វើជាមធ្យោបាយក្នុងការចង ក្រងប្រវត្តិ សាស្ត្ររបស់ ខ្មែរពីសម័យបុរាណនោះមកដែរ។ប៉ុន្តែ រហូតមកដល់ពេលសព្វថ្ងៃឆ្នាំ២០១១នេះ ចលនាកាសរសេរ ឬសូត្រកំណាព្យហាក់ពុំត្រូវ បានគេនឹក ឃើញ ក្រៅតែអំពីកម្មវិធីក្នុងទូរទស្សន៍មួយចំនួន ដែលផ្សព្វផ្សាយតែផ្នែកតូចមួយនៃកំណាព្យប៉ុណ្ណោះ។

**Sources: http://khmersme.wordpress.com**

ជាយូរលង់ណាស់មកហើយ ការចងក្រងឯកសារ ឬការនិពន្ធ ពណ៌នាអំពីអ្វីផ្សេងៗ របស់ ខ្មែរ គឺខ្មែរយើង តែងតែ សរសេរជាកំណាព្យ ហើយ ចំពោះរឿងនិទាន ឬរឿងប្រឌិតនានា ក៏គេសរសេរជា កំណាព្យដែរ ដែលភាសាអ្នក និពន្ធហៅថា ប្រលោមកំណាព្យ។

តាមសៀវភៅមេកាព្យរបស់លោកសាស្ត្រាចារ្យអៀង សាយ បាន សរសេរបែងចែកមេកាព្យជាពីរ ដោយ មួយជា មេកាព្យ ដែលមាន បែបបទល្អត្រឹមត្រូវ ឯមួយផ្នែកទៀត ជាមេកាព្យ ដែលមិនមានលក្ខណៈល្អ គ្រប់គ្រាន់ និង មានលំនាំស្រដៀងៗគ្នា។ មេកាព្យផ្នែកទីមួយមាន៣២មេ ក្នុងនោះមាន

១.បទកាក គតិ ២.បទព្រហ្មគីតិ ៣.បទពុំ នោល ៤.បន្ទោលកាក ៥.បទភុជង្គលីលា .៦ បទពាក្យ៧ ៧.បទ នមោ ៨.ក.ខ ៩.បទគោព័ន្ធស្នឹង ១០.បទនាគគៀវក្រវាត់១១.បទអក្សរសង្វាស ១២.បទ កង្កែបលោតក ណ្ដាលស្រះ ១៣.បទ អក្សរលូន ១៤.បទថយក្រោយ១៥.បទ ពាក្យ៨ ១៦.បទ នាគបរិព័ន្ធ១៧.បទ ត្រីពិធ ព័ន្ធ ១៨.បទ នាគរាជប្លែងរិទ្ធ ១៩.បទ ពាក្យ៩២០.បទ ផ្កាឈូករីក ២១.បទ ក្របចក្កវាឡ ២២.បទរលក ខ្ទប់ច្រាំង ២៣.បទ កង្កែបលោតស្លាក់ពេជ្យ២៤.បទ សារថីទាញរថ ២៥.បទ សឹង្ហតោលេងកន្ទុយ ២៦. បទ ពាក្យ១០ ២៧.បទ ត្រឡាចឡើងទ្រើង២៨.បទ ពាក្យ១១ ២៩.បទ ឆ័ត្របីជាន់ ៣០.បទ ជាប់ទង ៣១.បទ មករខ្ជាក់កែវ ៣២.បទ កង្កែមលោតលើគោក។

ចំណែកផ្នែកទីពីរមាន១៤មេ ដូចតទៅនេះ ១.បទ សបាត់សប៉ឹង ២.បទពស់លេបកន្ទុយ ៣.បទសាឡាប លន ៤.បទ ព្រះច័ន្ទបាំងឆ័ត្រ ៥.បទ វង្សវិចិត្រ ៦.បទ កង្កែមលោតផ្ទាត់ ខ្ទៅ ៨.បទ យុត្តិភ័ង្គ ៩។បទ រមាំង ដើរព្រៃ ១០.បទសហា ១១.បទ សត្វកាងស្លាប ១២.បទវិវិធមាលី ១៣.បទ សោទិនវិសាល ១៤.បទ សុក្រទិនវិសាល។

កំណាព្យ ឬកាព្យខ្មែរ ត្រូវបានគេសិក្សារកឃើញថា មាន៥៤បទផ្សេងគ្នា ក្នុងនោះមាន ១.បទ មេបួន ២. បថ្យាវត្ត ៣.កាកគតិ ៤.ព្រហ្មគិតិ ៥.ពុំនោល ៦.បន្ទោលកាក.៧ភុជង្គលីលា ៨.ពាក្យ៦ ៩.ពាក្យ៧ ១០. ពាក្យ៨ ១១.ពាក្យ៩ ១២.ពាក្យ១០ ១៣.ពាក្យ១១ ១៤. ក.ខ ១៥.បទនមោ. ១៦.បទអក្សរលូន ១៧.បទ អក្សរសង្វាស់ ១៨. កង្កែបលោតកណ្ដាលស្រះ ១៩. កង្កែបលោតលើគោក ២០.កង្កែបលោតស្លាកពេជ្រ ២១. កង្កែបលោតផ្ទាត់ខ្ទៅ ២២.នាគបរិព័ន្ធ ២៣.នាគគៀវក្រវាត់ ២៤.នាគបំប្លែងឫទ្ធ ២៥.គោព័ន្ធស្នឹង ២៦.សឹង្ហតោលេងកន្ទុយ ២៧. រមាំងដើរព្រៃ ២៨.ផ្កាឈូករីក ២៩.ក្របចក្រវាឡ ៣០.មុរខ្ជាក់កែវ ៣១. ឆ័ត្របីជាន់ ៣២.រលក យោលយាវ ៣៣.រលកខ្ទប់ច្រាំង ៣៤.សហា ៣៥.វិវិធមាលី ៣៦. ពស់លេប កន្ទុយ ៣៧. សត្វ កាងស្លាប ៣៨.ថយក្រោយចូលព្រៃក ៣៩.រមាំងបើកបាស់ ៤០. ទន្សាយទីសទាស ៤១.មាន់ ទឹកបណ្ដើរកូន ៤២.សារថីទាញរថ ៤៣. អើយរ៉ា ៤៤.សុក្រទិនវិសាល ៤៥.សោទិនវិសាល ៤៦. ត្រឡាចឡើងទ្រើង ៤៧.យត្តិភ័ង្គ ៤៨. ជាប់ទង ៤៩.សបាត់សប៉ឹង ៥០.ត្រីពិធព័ន្ធ ៥១. សឡាបលូន ៥២. វង្សវិចិត្រ ៥៣.ព្រះច័ន្ទបាំឆ័ត្រ ៥៤. ឥន្ទ្រជិត។